# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ




**បាត់ដំបង, ថ្ងៃទី ១០-១១ ខែ មិថុនា ឆ្នាំ ២០១០**

**បន្ទប់ប្រជុំរបស់មន្ទីរសុខាភិបាលខេត្ត**

**រៀបចំដោយ**

**ឧបត្ថម្ភដោយ**

Family Health International
អង្គការសុខភាពគ្រួសារអន្តរជាតិ

## ១. សមាសភាពចូលរួមមាន :

គណៈអធិបតីដែលចូលរួមក្នុងពិធីបើកកិច្ចប្រជុំនេះមានៈ

- ឯកឧត្តមវេជ្ជ. **ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
- លោកវេជ្ជ. **មាស វុឌ្ឍី** អនុប្រធានមជ្ឈប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- លោកវេជ្ជ. **ញឹក ចុំនឈុប** ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង

សិក្ខាកាមដែលចូលរួម មានចំនួន ៤៤ រូប ដែលជាសមាជិកក្រុមថែទាំ-ព្យាបាលជំងឺអេដស៍ លើកុមារ និងមនុស្សពេញវ័យ ,សេវាជំងឺរបេង,មន្ទីរពិសោធន៍,ក្រុមថែទាំតាមផ្ទះ,អ្នកសំរបសំរួល MMM និង mmm អ្នកផ្តល់ប្រឹក្សាផ្ទែក VCCT ដែលអញ្ជើញមកពីស្រុកប្រតិបត្តិមោងឬស្សី ខេត្តបាត់ដំបង និង ស្រុកប្រតិបត្តិប៉ៃលិន ខេត្តប៉ៃលិន និងបណ្តាអង្គការមួយចំនួន ដូចជា អង្គការ FHI ,US-CDC ។

## ២. អ្នកសំរបសំរួលវគ្គ/អ្នកចូលរួម :

| | | |
|---|---|---|
| ១- | លោកវេជ្ជ. មាស វុឌ្ឍី | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ២- | លោកវេជ្ជ. ស៊ិត សុវណ្ណរិទ្ធិ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៣- | លោកវេជ្ជ ស៊ុយ ដូនីន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៤- | លោកវេជ្ជ. ស៊ឹម សុផៃ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៥- | លោក កែវ វណ្ណៈ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៦- | លោក ស៊ុន សុខ លេង | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៧- | លោក ប៊ិត រ៉ាវី | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៨- | លោកវេជ្ជ. យុន គីមអ៊ាម | មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន |
| ៩- | លោកវេជ្ជ. ជា ម៉ានិត | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |
| ១០- | លោកវេជ្ជ. សេង សៅរិទ្ធ | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |
| ១១- | លោកវេជ្ជ. ណារិទ្ធ រដ្ឋា | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |

## ៣. ផ្នែកគណៈលេខា

១- លោក តូច វិសាល

## ៤. សកម្មភាព :

### គោលបំណង:

- ផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការស្រាវជ្រាវ រកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគអេដស៍ ។
- បង្កើនចំណេះដឹង និងជំនាញចាំបាច់ទាក់ទងនឹងការអនុវត្តន៍យុទ្ធសាស្ត្រ 3I's ជូនដល់មន្ត្រីផ្តល់សេវាថែទាំ-ព្យាបាល សំរាប់អ្នកផ្ទុកមេរោគអេដស៍ ដោយផ្តោតលើ ប្រធានបទខាងក្រោម:
  - ១- បង្កើនការស្រាវជ្រាវអ្នកជំងឺរបេងថ្មី ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ថ្មី តាមរយៈការសាកសួររករោគសញ្ញាទាំងបី
  - ២- ការប្រើប្រាស់គំនូសបំព្រួញសំរាប់ការផ្តល់ការព្យាបាលបង្ការជំងឺរបេងដោយ ប្រើឱសថ Isoniazid (IPT)
  - ៣- ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើប័ណ្ណពិនិត្យសុខភាពរក រោគសញ្ញាជំងឺរបេងសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងការព្យាបាលបង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid (IPT)
  - ៤- ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (diagnostic workup) រកជំងឺរបេងក្នុង ចំណោមអ្នកផ្ទុកមេរោគអេដស៍
  - ៥- ចំណេះដឹងមូលដ្ឋានស្តីអំពីការធ្វើតេស្តទុយប៊ែគុលលីន លើស្បែក (Tuberculin Skin Test-TST)
  - ៦- ការផ្តល់ការគាំទ្រសំរាប់ការប្រើប្រាស់ឱសថ Isoniazid ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ IPT
  - ៧- ការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត
  - ៨- ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៍ត្រួតពិនិត្យតាមដាននៃនិយាមនៃ បែបបទសំរាប់អនុវត្តយុទ្ធសាស្ត្រ 3Is
- រៀបចំផែនការ សំរាប់យុទ្ធសាស្ត្រ 3Is នៅសេវាថែទាំ-ព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគ អេដស៍ នៃមន្ទីរពេទ្យបង្អែកកំពង់ចាម និងស្រុកត្បូងឃ្មុំ ។

### ថ្ងៃទី១: ១០ ខែ មិថុនា ២០១០

- O មតិស្វាគមន៍របស់ **លោកវេជ្ជ ញ៉ឹក ប៊ុន ឈុន** ប្រធានមន្ទីរសុខាបាលខេត្តបាត់ដំបង
- O ចំណាប់អារម្មណ៍របស់**លោកវេជ្ជ មាស វុឌ្ឍី** អនុប្រធាមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

- ចំណាប់អារម្មណ៍ និងពិធីបើកកិច្ចប្រជុំដោយ **ឯកឧត្តម ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

☞ ការបង្ហាញពីកម្មវិធី និងគោលនៃកិច្ចប្រជុំ ដោយ**លោកវេជ្ជ. ស៊ីរិត សុវណ្ណារិទ្ធិ**

☞ ការបង្ហាញពីផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការ ស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង នៅតាមបណ្តុសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគ អេដស៍ ដោយ**លោកវេជ្ជ. ស៊ីរិត សុវណ្ណារិទ្ធិ និង ឃុន គីម អ៊ាម**

☞ ការពិភាក្សាទូទៅ **សំរបសំរួលដោយមន្ត្រី** NCHADS & CENAT

☞ ការព្យាបាលបង្ការជំងឺរបេងដោយឱសថ soniazid បង្ហាញដោយ **លោកវេជ្ជ. ឃុន គីមអ៊ាម**

☞ ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើបណ្ណ័ពិនិត្យសុខភាពរោគ សញ្ញាជំងឺរបេង បង្ហាញដោយ **លោកវេជ្ជ. ស៊ីរិត សុវណ្ណារិទ្ធិ/ លោក កែវ វណ្ណៈ**

☞ ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (Diagnostic Workup) រកជំងឺរបេង បង្ហាញដោយ **លោកវេជ្ជ. ឃុន គីម អ៊ាម/ ជា ម៉ានិត**

☞ ចំណេះដឹងមូលដ្ឋាន ស្តីពីការធ្វើតេស្ត ទុយប៉ែគុលលីន លើស្បែក បង្ហាញដោយ **លោកវេជ្ជ. ឃុន គីម អ៊ាម/សេង សោរិទ្ធ**

☞ ការផ្តល់ការគាំទ្រ សំរាប់ការប្រើប្រាស់ឱសថ អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ការព្យាបាលបង្ការជំងឺរបេង ដោយឱសថ Isoniazid បង្ហាញដោយ **លោកវេជ្ជ. សេង វុធី/លោកស្រីវេជ្ជ. ស៊ុយ ដូនីន**

**ថ្ងៃទី២: ១១ ខែ មិថុនា ២០១០**

☞ ការបង្ការការចំលងមេរោគរបេង នៅតាមបណ្តុសេវា ថែទាំ-ព្យាបាលបន្ត បង្ហាញដោយ **លោកវេជ្ជ. ណារិទ្ធ រដ្ឋា/ ជា ម៉ានិត**

☞ ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៏ ត្រួតពិនិត្យតាមដាននៃ និយាមនៃបែបបទ សំរាប់អនុវត្តយុទ្ធសាស្ត្រ Three I's បង្ហាញដោយ**លោក ស៊ុន សុខ ឡេង/កែវ វណ្ណៈ**

☞ ការពិភាក្សាជាក្រុមៈ **ការលើកផែនការ សំរាប់អនុវត្តនូវសកម្មភាពនៃការ អនុវត្តន៏យុទ្ធសាស្ត្រ** Three I's **នៅសេវាថែទាំ-ព្យាបាលបន្ត** សំរបសំរួលដោយមន្ត្រី NCHADS និង CENAT

☞ ការបង្ហាញពីលទ្ធផលនៃការពិភាក្សាជាក្រុម **សំរបសំរួលដោយមន្ត្រី** NCHADS និង CENAT

☞ សិក្ខាកាមនៃស្រុកប្រតិបត្តិទាំងពីរ បានឯកភាពគ្នា នឹងចាប់ផ្តើមដំណើរ នូវយុទ្ធសាស្ត្រ 3 Is នេះ ក្នុងខែ កក្កដា ឆ្នាំ ២០១០ បន្ទាប់ពី មជ្ឈមណ្ឌលទាំងពីផ្គត់ផ្គង់ សំភារៈ និងឱសថ រួចរាល់ ។

# លទ្ធផលនៃការវាយតំលៃកិច្ចប្រជុំ :

| | វែងពេក | សមរម្យ | ខ្លី | ខ្លីពេក |
|---|---|---|---|---|
| ១. រយៈពេល | ០០ | ១៥ | ២៧ | ០០ |
| | **ល្អ** | **បង្គួរ** | **មធ្យម** | **ខ្វះខាត** |
| ២. ទីកន្លែង | ៣៨ | ០២ | ០២ | ០០ |
| ៣. ការរៀបចំវគ្គបណ្តុះបណ្តាល | ២៥ | ១៥ | ០២ | ០០ |
| ៤. ខ្លឹមសារមេរៀន | ២៨ | ១០ | ០៤ | ០០ |
| ៥. ការបង្រៀន និងការសំរបសំរួល | ២០ | ១៥ | ០៧ | ០០ |
| ៦. ឯកសារសំរាប់សិក្ខាកាម | ៣០ | ០៨ | ០៤ | ០០ |

៧. ចំណេះដឹង និងជំនាញ ចំនួន បី ដែលសិក្ខាកាមបានទទួលពីវគ្គបណ្តុះបណ្តាល

៧.១- ចំណេះដឹង

- ការស្រាវជ្រាវជំងឺរបេង
- ការគ្រប់គ្រងការចំលងរោគរបេង
- ការបំពេញទំរង់បញ្ជូន
- ការថែទាំ និងព្យាបាលបន្ត

៧.២- ជំនាញ

- រោគសញ្ញារបេង
- កែសំរួលប្រពន្ធ័ខ្យល់
- ការផ្តល់ឱសថ អ៊ីសូឌីញ៉ាស៊ីដ
- បញ្ជូនរបាយការណ៍
- របៀបធ្វើតេស្ត TST

៨. តើមានប្រធានបទណាខ្លះ ដែលអ្នកចង់ដាក់បញ្ចូលបន្ថែមទៀត នៅក្នុងសិក្ខាសាលា?

២. ប្រធានបទ ស្តីពីការថត X-Ray

៣. ប្រធានបទ ស្តីពីរបៀបធ្វើតេស្តរបេង លើកុមារ និងកំហុសឆ្គងទាំងឡាយណា ដែលនាំអោយតេស្តរបេង មិនធម្មតា

៩. តើអ្នកយល់ថា ត្រូវកែលំអវគ្គសិក្ខាសាលានេះ យ៉ាងដូចម្តេច ដើម្បីអោយមានលក្ខណៈប្រសើរ សំរាប់វគ្គក្រោយៗទៀត?

១. រយៈពេលខ្លីពេក

២. Slides មួយចំនួនជាភាសារ English ពិបាកយល់

១០. សំណូមពរ សំរាប់វគ្គក្រោយ

១. សុំវគ្គបណ្តុះបណ្តាលនេះ វែងជាងនេះបន្តិច

២.  សុំប្រាក់លើកទឹកចិត្ត

៣.  សុំ ម៉ាស និងស្រោមដៃ ដើម្បីប្រើប្រាស់

៤.  សុំស្រោមអនាម័យ

៥.  សុំចុះអភិបាលអោយបានញឹកញាប់

ពិធីបិទវគ្គប្រព្រឹត្តទៅ ដោយមានវត្តមានគណអធិបតីរចូលរួមដូចជា

- មតិស្វាគមន៍របស់ **លោកវេជ្ជ ញឹក ប៊ុន ឈុប** ប្រធានមន្ទីរសុខាបាលខេត្តបាត់ដំបង
- ចំណាប់អារម្មណ៏របស់**លោកវេជ្ជ មាស វុឌ្ឍី** អនុប្រធាមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- ចំណាប់អារម្មណ៏ និងពិធីបើកកិច្ចប្រជុំដោយ **ឯកឧត្តម ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន

កិច្ចប្រជុំនេះបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ៥និង ០០ នាទី ល្ងាច បន្ទាប់ពីបានបូក សរុបកិច្ចប្រជុំ និងការថ្លែងសុន្ទរកថាបិទដោយ **ឯកឧត្តម ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន ។

បានឃើញ និងឯកភាព
ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ
នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ មាន_ឈីវុន

ភ្នំពេញថ្ងៃទី  ១៤  ខែ មិថុនា  ឆ្នាំ ២០១០
អ្នកធ្វើរបាយការណ៏

លោក កែវ វណ្ណៈ